**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៣០៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការសម្របសម្រួលការងារ សម្រាប់យន្តការវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០២១/០១៤ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧២៣/១៥៦៣ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីការបង្កើតគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៦០ អនក្រ.បក ចុះថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងតាមសំណើរបស់ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

### សម្រេច

### ជំពូកទី១

### បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ "**គណៈកម្មាធិការសម្របសម្រួលការងារសម្រាប់យន្តការវេទិការាជរដ្ឋាភិបាល- ផ្នែកឯកជន**" សរសេរជាអក្សរកាត់ថា "**គ.ស.វ.ជ.**" ។

## ជំពូកទី២

## សមាសភាព និងរចនាសម្ព័ន្ធ

**មាត្រា២ .-**

**គ.ស.រ.ជ.** មានសមាសភាពដូចតទៅ ÷

| | | |
|---|---|---|
| ១-ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | | ប្រធាន |
| ២-អគ្គលេខាធិការគណៈកម្មាធិការវិនិយោគកម្ពុជា | | អនុប្រធានប្រចាំការ |
| ៣-រដ្ឋលេខាធិការទីស្ដីការគណៈរដ្ឋមន្ត្រី | ១ (មួយ) រូប | អនុប្រធាន |
| ៤-រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ១ (មួយ) រូប | អនុប្រធាន |
| ៥-រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | ១ (មួយ) រូប | អនុប្រធាន |
| ៦-រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | ១ (មួយ) រូប | អនុប្រធាន |
| ៧-រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ១ (មួយ) រូប | សមាជិក |
| ៨-រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ១ (មួយ) រូប | សមាជិក |
| ៩-រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | ១ (មួយ) រូប | សមាជិក |
| ១០-រដ្ឋលេខាធិការក្រសួងរ៉ែនិងថាមពល | ១ (មួយ) រូប | សមាជិក |
| ១១-រដ្ឋលេខាធិការក្រសួងផែនការ | ១ (មួយ) រូប | សមាជិក |
| ១២-រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | ១ (មួយ) រូប | សមាជិក |
| ១៣-រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ១ (មួយ) រូប | សមាជិក |
| ១៤-រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ១ (មួយ) រូប | សមាជិក |
| ១៥-រដ្ឋលេខាធិការក្រសួងបរិស្ថាន | ១ (មួយ) រូប | សមាជិក |
| ១៦-រដ្ឋលេខាធិការក្រសួងធនធានទឹកនិងឧតុនិយម | ១ (មួយ) រូប | សមាជិក |
| ១៧-រដ្ឋលេខាធិការក្រសួងព័ត៌មាន | ១ (មួយ) រូប | សមាជិក |
| ១៨-រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | ១ (មួយ) រូប | សមាជិក |
| ១៩-រដ្ឋលេខាធិការក្រសួងសុខាភិបាល | ១ (មួយ) រូប | សមាជិក |
| ២០-រដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន | ១ (មួយ) រូប | សមាជិក |
| ២១-រដ្ឋលេខាធិការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | ១ (មួយ) រូប | សមាជិក |
| ២២-រដ្ឋលេខាធិការក្រសួងទេសចរណ៍ | ១ (មួយ) រូប | សមាជិក |
| ២៣-រដ្ឋលេខាធិការក្រសួងកិច្ចការនារី | ១ (មួយ) រូប | សមាជិក |

២៤-រដ្ឋលេខាធិការក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ១ (មួយ) រូប សមាជិក
២៥-រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ១ (មួយ) រូប សមាជិក
២៦-អគ្គទេសាភិបាលរងធនាគារជាតិនៃកម្ពុជា ១ (មួយ) រូប សមាជិក
២៧-អគ្គលេខាធិការរងគណៈកម្មាធិការវិនិយោគកម្ពុជា ១ (មួយ) រូប លេខាធិការ ។

សមាសភាពជាក់ស្តែងនៃ **គ.ស.រ.ឯ.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល ។

**មាត្រា៣ .-**

**គ.ស.រ.ឯ.** អាចមានអនុគណៈកម្មាធិការនិងក្រុមការងារតាមវិស័យ ដើម្បីអនុវត្តភារកិច្ចដូចមានចែងក្នុងមាត្រា៤ នៃអនុក្រឹត្យនេះតាមការចាំបាច់។ អនុគណៈកម្មាធិការ និងក្រុមការងារតាមវិស័យរបស់ **គ.ស.រ.ឯ.** ត្រូវបង្កើតឡើងដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

## ជំពូកទី៣
## តួនាទី និងភារកិច្ច

**មាត្រា៤ .-**

**គ.ស.រ.ឯ.** មានតួនាទីនិងភារកិច្ចដូចតទៅ ÷

- ជាសេនាធិការរួមរបស់រាជរដ្ឋាភិបាល ក្នុងកិច្ចការសម្របសម្រួលនិងរៀបចំវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន
- ទទួលបន្ទុកសម្របសម្រួលរៀបចំបង្កើតក្រុមការងារតាមវិស័យសម្រាប់ពិភាក្សាការងារជាមួយវិស័យឯកជនតាមសេចក្តីត្រូវការចាំបាច់
- ជាច្រកចេញ-ចូលតែមួយ របស់រាជរដ្ឋាភិបាលក្នុងការសម្របសម្រួល ពិនិត្យ និងប្រមូលសរុបនូវបញ្ហាប្រឈម និងសំណូមពរនានា ដែលត្រូវបានលើកឡើងដោយក្រុមការងារតាមវិស័យទាំងអស់
- ពិនិត្យ និងបែងចែកនូវបញ្ហាប្រឈម និងសំណូមពរនានាពីវិស័យឯកជន នៅក្រោមយន្តការវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជនទៅឱ្យក្រសួង-ស្ថាប័នមានសមត្ថកិច្ច ដើម្បីពិនិត្យនិងដោះស្រាយ។ ដោយឡែកចំពោះបញ្ហាដែលពាក់ព័ន្ធនឹងគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ស្ថិតនៅក្រោមសមត្ថកិច្ចរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា/គណៈកម្មាធិការវិនិយោគកម្ពុជា (ក.អ.ក./គ.វ.ក.) គឺ ក.អ.ក./គ.វ.ក. ត្រូវខិតខំដោះស្រាយ។ ក្នុងករណី ដែលបញ្ហាមានចរិតលក្ខណៈជាប្រព័ន្ធ និងជារចនាសម្ព័ន្ធនៃការកែទម្រង់ពាក់ព័ន្ធនឹងគោលនយោបាយ ឬអន្តរវិស័យ បញ្ហានេះ ត្រូវក្លាយជាកម្មវត្ថុនៃការដោះស្រាយដោយគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (គ.ស.ហ.)។ ក្នុងករណី ក.អ.ក./គ.វ.ក. ឬ គ.ស.ហ. ពុំអាចដោះស្រាយបញ្ហាដូចបានរៀបរាប់ខាងលើ ក.អ.ក./គ.វ.ក. ឬ គ.ស.ហ. ត្រូវរាយការណ៍ជូននាយករដ្ឋមន្ត្រី ដើម្បីផ្តល់អនុសាសន៍ និងដំណោះស្រាយនៅក្នុងវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន

- សម្របសម្រួលដាក់ចេញសេចក្តីជូនដំណឹង ស្តីពីវិធានការនានា ដែលរាជរដ្ឋាភិបាលបានសម្រេចនៅក្នុងវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន
- ទទួលបន្ទុកតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តវិធានការនានាដែលបានដាក់ចេញនៅក្រោមយន្តការវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន
- តាមដាន និងជំរុញការអនុវត្តភារកិច្ចនៃក្រុមការងារតាមវិស័យនីមួយៗ ព្រមទាំងតាមដានវឌ្ឍនភាពក្នុងការដោះស្រាយបញ្ហាពីស្ថាប័នមានសមត្ថកិច្ច
- រៀបចំរបាយការណ៍អំពីវឌ្ឍនភាពនៃកិច្ចដំណើរការរបស់ក្រុមការងារតាមវិស័យនីមួយៗ និងសមិទ្ធផលសំខាន់ៗជូនរាជរដ្ឋាភិបាល,
- ទទួលបន្ទុកបូកសរុប និងផ្សព្វផ្សាយលទ្ធផលនៃវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន ។

## ជំពូកទី៤
## ដំណើរការការងារ

**មាត្រា៥ .-**

តាមការអញ្ជើញរបស់ប្រធាន អនុប្រធាននិងសមាជិក គ.ស.រ.ឯ. ត្រូវចូលរួមប្រជុំឬចាត់តាំងតំណាងដែលមានសិទ្ធិសម្រេចជំនួស ដើម្បីចូលរួមប្រជុំក្នុងករណីអវត្តមានឬមានធុរៈ ។

ក្នុងករណីប្រធានអវត្តមាន គ.ស.រ.ឯ. អាចដំណើរការប្រជុំក្រោមអធិបតីភាពរបស់អនុប្រធាន ឬតំណាងតាមការប្រគល់សិទ្ធិរបស់ប្រធាន។

**មាត្រា៦ .-**

គ.ស.រ.ឯ. មានសិទ្ធិអញ្ជើញថ្នាក់ដឹកនាំក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធចូលរួមប្រជុំនិងបំពេញការងារតាមការចាំបាច់។

គ.ស.រ.ឯ. មានសិទ្ធិអញ្ជើញតំណាងដៃគូអភិវឌ្ឍន៍ តំណាងវិស័យឯកជន និងតំណាងសង្គមស៊ីវិលចូលរួមប្រជុំក្នុងឋានៈជាសមាជិក ឬអ្នកសង្កេតការណ៍តាមការចាំបាច់។

**មាត្រា៧ .-**

គ.ស.រ.ឯ. មានសិទ្ធិប្រើត្រារបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាសម្រាប់ដំណើរការការងាររបស់ខ្លួន។

## ជំពូកទី៥
## អវសានបញ្ញត្តិ

**មាត្រា៨ .-**

អនុក្រឹត្យលេខ៤១ អនក្រ.បក ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៤ ស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍវិស័យឯកជននិងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៩ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១១ រោច ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៨ ខែធ្នូ ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា**

**ស៊ុន ចាន់ថុល**

**កន្លែងទទួល÷**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៩
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**បញ្ជីក្រុមការងារទាំង ១៤ នៃវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន លើកទី១៩**

១) ក្រុមការងារ កសិកម្ម និង កសិឧស្សាហកម្ម «ក»

២) ក្រុមការងារ ទេសចរណ៍ «ខ»

៣) ក្រុមការងារ កម្មន្តសាល និង សហគ្រាសធុនតូច និងមធ្យម និងសេវា «គ»

៤) ក្រុមការងារ នីតិកម្ម ពន្ធដារ និង អភិបាលកិច្ច «ឃ»

៥) ក្រុមការងារ សេវាធនាគារ និង ហិរញ្ញវត្ថុ «ង»

៦) ក្រុមការងារ ដឹកជញ្ជូន និង ហេដ្ឋារចនាសម្ព័ន្ធ «ច»

៧) ក្រុមការងារ ផលិតកម្មកែច្នៃសម្រាប់ការនាំចេញ និង កិច្ចសម្រួលពាណិជ្ជកម្ម «ឆ»

៨) ក្រុមការងារ ទំនាក់ទំនងវិជ្ជាជីវៈ «ជ»

៩) ក្រុមការងារ ស្រូវ-អង្ករ «ឈ»

១០) ក្រុមការងារ ថាមពល និង ធនធានរ៉ែ «ញ»

១១) ក្រុមការងារ អប់រំ «ដ»

១២) ក្រុមការងារ សុខាភិបាល «ឋ»

១៣) ក្រុមការងារ សំណង់ និង អចលនទ្រព្យ «ឌ»

១៤) ក្រុមការងារ ផ្នែកសេវាហិរញ្ញវត្ថុមិនមែនធនាគារ «ឍ»